# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ្នកនាំពាក្យ គ.ជ.ប**

**លេខ ១៥២ គ.ជ.ប**

ថ្ងៃពុធ ១២រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## សេចក្តីសម្រេច
## របស់ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប លើសំណុំរឿងលេខ ០០១

នៅព្រឹកថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជំនុំជម្រះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបើកសវនាការជាសាធារណៈលើសំណុំរឿងលេខ ០០១ នៅសាលសន្និសីទ គ.ជ.ប និងចូលរួមដោយមេធាវីដើមបណ្តឹងជំទាស់ មេធាវីចុងបណ្តឹងជំទាស់ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ។

សំណុំរឿងលេខ ០០១ គឺពាក់ព័ន្ធនឹងយុទ្ធនាការម្រាមដៃស្អាតដែលគណៈកម្មការរៀបចំការបោះឆ្នោតខេត្តបាត់ដំបង បានសម្រេចផាកពិន័យទៅលើបុគ្គលចំនួន ៥ នាក់ ក្នុងម្នាក់ៗ ១០លានរៀល។

ក្រោយពីបានស្តាប់ចម្លើយរបស់គូរភាគី ពិនិត្យភស្តុតាង និងក្រោយពីបានពិភាក្សាស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត នៅវេលាម៉ោង ១៥:១៥ នាទី ថ្ងៃដដែល ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ៖

- សកម្មភាពជួបជុំ និងថតរូបបង្ហោះម្រាមដៃស្អាត គឺជាការផ្តួចផ្តើមគំនិតរបស់ឈ្មោះ **ជា ជីវ** ។ ក្រោយពីបញ្ចប់ការជួបជុំ លោក **ជា ជីវ** លោក **គ្រុយ គឹមសាំង** និងលោក **ថោង សារឿន** បានបង្ហោះរូបថតនៅលើគណនីបណ្តាញសង្គម (Facebook) របស់ខ្លួនដោយមានសរសេរពាក្យពេចន៍ដូចជា *"ម្រាមដៃខ្ញុំពិតជាស្អាត ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ និងម្រាមដៃស្អាត"* ហើយបាន Tag ឱ្យឈ្មោះគណនីបណ្តាញសង្គម (Facebook) ឈ្មោះ **ម៉ាង ឈុន** និងឈ្មោះ **ពៅ តាំង** ។
- សកម្មភាពយុទ្ធនាការម្រាមដៃស្អាតនេះ បានធ្វើឱ្យមានព្យសនកម្មដល់អត្រានៃអ្នកចេញទៅបោះឆ្នោត និងអត្រានៃសន្លឹកឆ្នោតមិនបានការ ពីព្រោះថា តាមប្រវត្តិនៃការបោះឆ្នោតសកលអត្រានៃអ្នកបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តែងខ្ពស់ជាងអត្រានៃអ្នកចេញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ជាក់ស្តែង ការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ អ្នកចេញទៅបោះឆ្នោតមានចំនួនជាង ៩០% ចំណែកឯការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ វិញ មានតែជាង ៨០% ប៉ុណ្ណោះ ។
- តាមប្រវត្តិនៃការបោះឆ្នោត អត្រានៃសន្លឹកឆ្នោតមិនបានការអាចមានចន្លោះពី ១% ទៅ ៣% ប៉ុណ្ណោះ ប៉ុន្តែការបោះឆ្នោតនៅឆ្នាំ២០១៨ អត្រានៃសន្លឹកឆ្នោតមិនបានការបានកើនឡើងដល់ជាង ៩% ។

ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេច ៖

- តម្កល់សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបាត់ដំបងដោយក្នុងនោះ តម្កល់ការផាកពិន័យចំនួន ១០ លានរៀល ទៅលើឈ្មោះ **ជា ជីវ** ។
- ផាកពិន័យជាប្រាក់ចំនួន ៥ លានរៀល ក្នុងម្នាក់ៗទៅលើឈ្មោះ **ថោង សារឿន** និងឈ្មោះ **គ្រុយ គឹមសាំង** ។
- លើកលែងការផាកពិន័យចំពោះឈ្មោះ **ម៉ាង ឈុន** និងឈ្មោះ **៣ តាំង** ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ចំពោះមុខគូភាគី និងបើកផ្លូវតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ តាមកំណត់ច្បាប់។

សេចក្តីសម្រេចពិស្តារនៃសំណុំរឿងលេខ ០០១ មានបង្ហោះនៅលើគេហទំព័រ គ.ជ.ប https://www.necelect.org.kh/khmer/content/3476 ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 959 666<br>Email : hangputhea@gmail.com | ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 518 485<br>Email : sovannaromhy@yahoo.fr |